ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# សេចក្តីជូនដំណឹង

## ស្តីពីកាលបរិច្ឆេទ និងកាលវិភាគនៃការប្រឡងប្រជែង ជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

ថ្ងៃ សុក្រ ៤កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលមានរាយនាម នៅក្នុងសេចក្តីសម្រេចលេខ ១០៣៥/២៤ មស.នកវអ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់បេក្ខជន នៃការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន សម្រាប់បង្រៀននៅអនុវិទ្យាល័យ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡងលើវិញ្ញាសាសរសេរលើកទី១ ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង៖** សំណួរពហុចម្លើយពាក់ព័ន្ធនឹងវប្បធម៌ទូទៅ(៣០%) និងមុខវិជ្ជាឯកទេសទី១ ឬ មុខវិជ្ជាឯកទេស សម្រាប់បរិញ្ញាបត្រ+១(៧០%) រយៈពេល ២ម៉ោង។

**ខ-កាលបរិច្ឆេទប្រឡង មណ្ឌលប្រឡង និងវេនប្រឡង៖**

១-ថ្ងៃព្រហស្បតិ៍ ទី២ ខែឧសភា ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖

**+វេនទី១៖** ចាប់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

**-រូបវិទ្យា-គីមីវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-រូបវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល បរិញ្ញាបត្រ+១)
**-អគ្គិសនី-អេឡិចត្រូនិច** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

**+វេនទី២៖** ចាប់ពីម៉ោង ១៦:០០នាទី ដល់ម៉ោង ១៨:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចជា៖

**-បារាំង-គណិតវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-បារាំង-ជីវវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-បារាំង-រូបវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-អង់គ្លេស-ICT** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-ICT-អង់គ្លេស** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)
**-កសិកម្ម-បសុវប្បកម្ម** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

២-ថ្ងៃសុក្រ ទី៣ ខែឧសភា ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៖

**+វេនទី១៖** ចាប់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

**-ខ្មែរ-សីលធម៌ ពលរដ្ឋ** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

**+វេនទី២៖** ចាប់ពីម៉ោង ១៦:០០នាទី ដល់ម៉ោង ១៨:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចជា៖

**-ខ្មែរ-សីលធម៌ ពលរដ្ឋ** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

៣-ថ្ងៃសៅរ៍ ទី៤ ខែឧសភា ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៖

+**វេនទី១៖** ចាប់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

-**ជីវវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+៤)

-**ជីវវិទ្យា-ផែនដីវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

+**វេនទី២៖** ចាប់ពីម៉ោង ១៦:០០នាទី ដល់ម៉ោង ១៨:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

-**គណិតវិទ្យា-រូបវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

៤-ថ្ងៃអាទិត្យ ទី៥ ខែឧសភា ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៖

+**វេនទី១៖** ចាប់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

-**គណិតវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល បរិញ្ញាបត្រ+១)

-**គីមីវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+៤)។

+**វេនទី២៖** ចាប់ពីម៉ោង ១៦:០០នាទី ដល់ម៉ោង ១៨:០០នាទី ចំពោះបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេស ដូចខាងក្រោម៖

-**ប្រវត្តិវិទ្យា-ភូមិវិទ្យា** (ប្រព័ន្ធបណ្តុះបណ្តាល ១២+២)។

❖ បញ្ជាក់៖

+**បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង ១ម៉ោងមុនការប្រឡងតាមវេនកំណត់ និងភ្ជាប់មកជាមួយនូវ៖**

-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬធាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

+**បេក្ខជនមិនត្រូវយកឯកសារផ្សេងៗ ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (ទូរស័ព្ទ នាឡិកាឆ្លាតវៃ...) ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត និងមិនមានការទទួលរក្សាទុកនោះទេ។**

+**ទីតាំងមណ្ឌល៖**

-**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖** ស្ថិតតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

-**សាលាភូមិន្ទរដ្ឋបាល៖** ស្ថិតតាមបណ្តោយវិថីឧកញ៉ាញឹកជូឡុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៖** ស្ថិតតាមបណ្តោយមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

+**សម្លៀកបំពាក់សមរម្យ៖**

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានម៉ឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**